# សហគមន៍ជាក់ជាំក្នុងខេត្តមណ្ឌលគិរី យកការអប់រំជារឿងសំខាន់

គណៈកម្មការទ្រទ្រង់សាលារៀន ធ្វើការផ្សព្វផ្សាយការយល់ដឹងអំពីតម្លៃនៃការអប់រំនៅក្នុងភូមិមួយដែលមានប្រជាជនរស់នៅភាគច្រើនជាជនជាតិភាគតិចព្នង ដើម្បីធ្វើការផ្លាស់ប្តូរផ្នត់គំនិតរបស់ម្តាយឪពុក និងសិស្សអំពីសារៈសំខាន់របស់សាលារៀន។

មេភូមិ សែន ទៀវ បានរស់នៅក្នុងភូមិជាក់ជាំ ក្នុងខេត្តមណ្ឌលគិរីតាំងពីពេលគាត់កើតមកម្លេះ ហើយបានបញ្ជាក់ថាអ្នករស់នៅក្នុងភូមិភាគច្រើនជាជនជាតិភាគតិចព្នង លើកលែងតែប្រជាជនមួយចំនួនប៉ុណ្ណោះដែលមិនមែនជាជនជាតិភាគតិចព្នង។

បុរសវ័យ៥១ឆ្នាំរូបនេះនិយាយថា ៖ "ខ្ញុំបានរស់នៅទីនេះតាំងពីកើតមកម្លេះ ហើយខ្ញុំអាចបញ្ជាក់បានថា ជនជាតិព្នងដែលរស់នៅក្នុងភូមិនេះមាន ៦០គ្រួសារ"។

គាត់ពន្យល់ដោយមានក្តីកង្វល់គួរសមថា ៖ "របៀបរស់នៅរបស់ប្រជាជនបានផ្លាស់ប្តូរហើយ នេះជាមូលហេតុធ្វើឱ្យពួកគេកាន់តែពិបាកក្នុងការរកលុយចិញ្ចឹមជីវិត"។

គាត់និយាយថា ៖ "ដូច្នេះទើបខ្ញុំបញ្ជូនកូនទាំង ៦នាក់របស់ខ្ញុំទៅរៀនដើម្បីមានចំណេះដឹងដូចគេ" ហើយបន្ថែមថា ៖ "ខ្ញុំយល់ថាការមានចំណេះដឹងគឺវាមានប្រយោជន៍ ព្រោះកូនខ្ញុំអាចមានការងារធ្វើជាគ្រូបង្រៀន ឬជាអ្នកបកប្រែឱ្យអង្គការមិនមែនរដ្ឋាភិបាល"។

ប៉ុន្តែលោក សែន ទៀវ ក៏ចង់ឱ្យយុវជនទាំងអស់ក្នុងភូមិមានក្តីសុបិន្តសម្រាប់អនាគត ដូចដែលគាត់មានសម្រាប់កូនគាត់ដូច្នេះដែរ។ នេះជាមូលហេតុដែលធ្វើឱ្យគាត់មានក្តីរីករាយដែលបានរៀនក្នុងអំឡុងវគ្គសិក្ខាសាលាមួយ ដែលរៀបចំដោយអង្គការឃែរ។ គាត់ដឹងថា ក្នុងនាមជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន ដែលគាត់បានធ្វើអស់រយៈពេល២ឆ្នាំមកហើយនោះគឺគាត់គួរផ្សព្វផ្សាយការយល់ដឹងអំពីតម្លៃនៃការអប់រំ និងគួរព្យាយាមរក្សាកុមារក្នុងចំនួនច្រើនតាមដែលអាចធ្វើទៅបានឱ្យបន្តការសិក្សា។

គាត់រំលឹកថា ៖ "ខ្ញុំបានដឹងអំពីតួនាទីរបស់គណៈកម្មការទ្រទ្រង់សាលារៀនបន្ទាប់ពីខ្ញុំបានទទួលការបណ្តុះបណ្តាលរួចមក។ ពីមុនគណៈកម្មការទ្រទ្រង់សាលារៀនមិនមានភាពសកម្មទេព្រោះយើងមិនបានដឹងអំពីភារកិច្ចនិងកាតព្វកិច្ចរបស់យើង"។

បន្ទាប់ពីគាត់បានទទួលការបណ្តុះបណ្តាលអំពីភារកិច្ចទទួលខុសត្រូវរបស់ខ្លួនរួចមក គាត់ព្រមទាំងសមាជិកដទៃទៀតក្នុងជួរគណៈកម្មការបានចាប់ផ្តើមអប់រំឪពុកម្តាយអំពីតម្លៃនៃការអប់រំ និងអត្ថប្រយោជន៍នៃការអប់រំសម្រាប់អនាគតកូនចៅរបស់ពួកគេ។


© Nicolas Axelrod / Ruom / CARE

*"ពីមុនឪពុកម្តាយមិនបានបញ្ជូនកូនមករៀន ឬសិស្សមិនបានមករៀនទៀងទាត់ទេ។ តែឥឡូវនេះឪពុកម្តាយ សិស្ស និងប្រជាជនក្នុងសហគមន៍ទាំងមូលមានការយល់ដឹងច្រើនជាងមុន អំពីសារៈសំខាន់នៃការរៀនសូត្រ ដូច្នេះហើយទើបឪពុកម្តាយបានបញ្ជូនកូនរបស់ពួកគេមករៀន ហើយសិស្សក៏មិនគេចសាលាដែរ"។*

គាត់បានធ្វើការងារនេះដោយចុះតាមផ្ទះ ពីផ្ទះមួយទៅផ្ទះមួយ និងអំឡុងពេលប្រជុំប្រចាំខែ ហើយឥឡូវនេះគណៈកម្មការទ្រទ្រង់សាលារៀនរៀបចំធ្វើការប្រជុំនេះជាមួយសហគមន៍។

គាត់ពន្យល់ថា ៖ "ពេលខ្លះសិស្សឈប់មករៀនព្រោះពួកគេត្រូវជួយឪពុកម្តាយរបស់គេនៅផ្ទះ ឬនៅស្រែចម្ការ"។

ប៉ុន្តែទោះជាដូច្នេះក៏ដោយ ក៏លោកសែន ទៀវ អះអាងថា ចាប់តាំងពីគណៈកម្មការទ្រទ្រង់សាលារៀនបានបំពេញភារកិច្ចទទួលត្រូវក្នុងអាណត្តិរបស់ខ្លួនមក ឪពុកម្តាយភាគច្រើនបានផ្លាស់ប្តូរឥរិយាបថរបស់ពួកគេចំពោះការអប់រំ។

គាត់និយាយថា៖ "ពីមុនឪពុកម្តាយមិនបានបញ្ជូនកូនមករៀន ឬសិស្សមិនបានមករៀនទៀងទាត់ទេ។ តែឥឡូវនេះ ឪពុកម្តាយ សិស្ស និងប្រជាជនក្នុងសហគមន៍ទាំងមូលមានការយល់ដឹងច្រើនជាងមុនអំពីសារៈសំខាន់នៃការរៀនសូត្រ ដូច្នេះហើយទើបឪពុកម្តាយបានបញ្ជូនកូនរបស់ពួកគេមករៀន ហើយសិស្សក៏មិនគេចសាលាដែរ"។

---

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

សហភាពអឺរ៉ុប

SWEDEN

unicef

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

*© CARE Cambodia, September  2016*